# ព្រឹត្តិបត្រព័ត៌មាន គ.ជ.ប
# NEC BULLETIN

លេខ ៣ ចេញផ្សាយថ្ងៃទី ៣១ ខែ តុលា ឆ្នាំ ២០១១


# ការពិនិត្យបញ្ជីឈ្មោះ និងចុះឈ្មោះបោះឆ្នោត ឆ្នាំ ២០១១



## ការផ្សព្វផ្សាយការងាររៀបចំការបោះឆ្នោត ដល់ស្ថាប័នពាក់ព័ន្ធ

ឯកឧត្តម អ៊ឹម សួស្ដី ប្រធាន គ.ជ.ប ថ្លែងក្នុងពិធីផ្សព្វផ្សាយច្បាប់បោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ និងច្បាប់ស្ដីពីវិសោធនកម្មនៃច្បាប់នេះ



មាតិកា


- ការផ្សព្វផ្សាយការងាររៀបចំការបោះឆ្នោត..............................................ទំព័រទី ២
- ចំនួនអ្នកសង្កេតការណ៍ និងតំណាងគណបក្សនយោបាយ.............................ទំព័រទី ៩
- ជំនួបពិភាក្សារវាង គ.ជ.ប ជាមួយតំណាង UNDP....................................ទីព័រទី ១២
- អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរដែលផុតកំណត់ត្រូវបានបន្តសុពលភាព.............ទំព័រទី ១៣
- ឯកឧត្តម អ៊ឹម សួស្ដី ប្រធាន គ.ជ.ប បានធ្វើជាអធិបតីក្នុងពិធីផ្សព្វផ្សាយ........ទំព័រទី ១៥



necinfo@forum.org.kh www.necelect.org.kh Fax/Phone: (023) 214 374, 214231, Tel: 012 855 018





# ការផ្សព្វផ្សាយការងាររៀបចំការបោះឆ្នោត ដល់ស្ថាប័នពាក់ព័ន្ធ

ក្រៅពីការផលិតសម្ភារអប់រំផ្សព្វផ្សាយដូចជា ស្ប៉តវិទ្យុ ស្ប៉តវីដេអូ ផូសស្ទើរ បដា ពាក្យស្លោក ការផ្សាយមេក្រូចល័ត និងកម្មវិធីស្វែងយល់ពីការបោះឆ្នោត ដើម្បីអប់រំផ្សព្វផ្សាយដល់អ្នកបោះឆ្នោតឱ្យមានការយល់ដឹងអំពីការបោះឆ្នោតនោះ គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត(គ.ជ.ប) បានផ្សព្វផ្សាយដោយផ្ទាល់ដល់គណបក្សនយោបាយអង្គការមិនមែនរដ្ឋាភិបាល អ្នកសារព័ត៌មានជាតិ និងអន្តរជាតិ តាមរយៈការរៀបចំកិច្ចប្រជុំជាប្រចាំរៀងរាល់សប្តាហ៍សំដៅធ្វើយ៉ាងណាឱ្យការងាររៀបចំការបោះឆ្នោតប្រព្រឹត្តទៅបានល្អប្រសើរ។ កម្មវិធីនេះមានចំនួន១៩លើក បាននឹងកំពុងដំណើរការចាប់តាំងពីខែសីហា ហើយនឹងបញ្ចប់នៅខែមករា ឆ្នាំ២០១២។

រាល់កិច្ចប្រជុំ-សន្និសីទសារព័ត៌មាននីមួយៗ ដែលរៀបចំនៅទីស្តីការ គ.ជ.ប មានប្រធានបទច្បាស់លាស់ និងតែងតែផ្សព្វផ្សាយចំណុចថ្មីៗទាក់ទងនឹងការងាររៀបចំការបោះឆ្នោត ដូចជាការពិនិត្យបញ្ជីឈ្មោះ និងចុះឈ្មោះបោះឆ្នោតឆ្នាំ២០១១ ការបោះឆ្នោតឡើងវិញជ្រើសរើសក្រុមប្រឹក្សាខណ្ឌពោធិ៍សែនជ័យ ការបោះឆ្នោតជ្រើសតាំងសមាជិកព្រឹទ្ធសភា នីតិកាលទី៣ ឆ្នាំ២០១២។

គិតត្រឹមថ្ងៃទី២៤ ខែតុលា ឆ្នាំ២០១១នេះ គ.ជ.ប បានរៀបចំកិច្ចប្រជុំ-សន្និសីទសារព័ត៌មាន បានចំនួន៨លើករួចមកហើយ រួមមាន ៖



ឯកឧត្តម អ៊ឹម សួស្ដី ប្រធាន គ.ជ.ប





**លើកទី១**_ សន្និសីទសារព័ត៌មាន ស្តីពីការពិនិត្យបញ្ជីឈ្មោះ និងចុះឈ្មោះបោះឆ្នោត។ សន្និសីទនេះបានប្រព្រឹត្តទៅ

# ការពិនិត្យបញ្ជីឈ្មោះ និងចុះឈ្មោះបោះឆ្នោត ឆ្នាំ២០១១



កាលពីថ្ងៃទី១៦ ខែសីហា ឆ្នាំ២០១១ ក្រោមអធិបតីភាព ឯកឧត្តម អ៊ឹម សួស្តី ប្រធាន គ.ជ.ប ដែលមានតំណាងគណបក្សនយោបាយ អង្គការមិនមែនរដ្ឋាភិបាល និងអ្នកសារព័ត៌មានជាតិ និងអន្តរជាតិ ប្រមាណ៧០នាក់ចូលរួមផងដែរ។ ក្នុងសន្និសីទនោះ ឯកឧត្តមប្រធាន គ.ជ.ប បានផ្សព្វផ្សាយពីចំណុចសំខាន់ៗដូចជា ៖

- ស្ថិតិប៉ាន់ស្មានប្រជាពលរដ្ឋរួម មានចំនួន**១៤.១៧៤.៩៤៩**នាក់ អ្នកដែលមានអាយុ១៨ឆ្នាំឡើងមាន**៨.៨៩៤.២១៩**នាក់ ក្នុងនោះមានស្ត្រី**៤.៦៣៦.៧២៧**នាក់។ ស្ថិតិប៉ាន់ស្មានប្រជាពលរដ្ឋដែលត្រូវចុះឈ្មោះបោះឆ្នោតឆ្នាំ២០១១មានចំនួន**៤៧៦.០៣៦**នាក់ ហើយការិយាល័យមានចំនួន**១៨.១២៦**ការិយាល័យ។
- ណែនាំអំពីនីតិវិធី និងការប្រើប្រាស់ទម្រង់ថ្មី គឺលិខិតបញ្ជាក់អត្តសញ្ញាណសម្រាប់បម្រើឱ្យការបោះឆ្នោត។
- ទម្រង់១០១៨ឈប់ឱ្យប្រើប្រាស់ គឺត្រូវចាត់ទុកជាមោឃៈ។
- មិនអនុញ្ញាតឱ្យជំពាក់រូបថតសម្រាប់បិទលើលិខិតបញ្ជាក់អត្តសញ្ញាណសម្រាប់បម្រើឱ្យការបោះឆ្នោត។
- ក្រុមប្រឹក្សាឃុំ សង្កាត់ និងស្មៀនមិនអនុញ្ញាតឱ្យធ្វើជាសាក្សីទេ។
- អំពាវនាវដល់គណបក្សនយោបាយ អង្គការមិនមែនរដ្ឋាភិបាល អ្នកសារព័ត៌មានជាតិ និងអន្តរជាតិឱ្យជួយផ្សព្វផ្សាយដល់ប្រជាពលរដ្ឋ អំពីការពិនិត្យបញ្ជីឈ្មោះ និងចុះឈ្មោះបោះឆ្នោត ព្រោះការមានឈ្មោះក្នុងបញ្ជីបោះឆ្នោតមានសារៈសំខាន់ណាស់។



*លោកជំទាវបណ្ឌិត ស៊ីន ជុំបូ អនុប្រធាន គ.ជ.ប*







**លើកទី២**_កិច្ចប្រជុំ ស្តីពីការពិនិត្យបញ្ជីឈ្មោះ និងចុះឈ្មោះបោះឆ្នោត ឆ្នាំ២០១១។ កិច្ចប្រជុំនេះបានប្រព្រឹត្តទៅកាលពីថ្ងៃទី៣០ ខែសីហា ឆ្នាំ២០១១ ក្រោមអធិបតីភាព លោកជំទាវបណ្ឌិត ស៊ីន ជុំបូ អនុប្រធាន គ.ជ.ប ដែលមានការចូលរួមពីតំណាងគណបក្សនយោបាយ អង្គការមិនមែនរដ្ឋាភិបាល និងអ្នកសារព័ត៌មានជាតិ និងអន្តរជាតិប្រមាណ ៦០នាក់។ លោកជំទាវបានលើកឡើងក្នុងកិច្ចប្រជុំនោះថា កន្លងមកនេះ រដ្ឋសភាបានអនុម័តវិសោធនកម្មច្បាប់បោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រលើ១៣មាត្រា ប៉ុន្តែមាត្រាសំខាន់ទាក់ទងនឹងការពិនិត្យបញ្ជីឈ្មោះ និងចុះឈ្មោះបោះឆ្នោតឆ្នាំនេះមានតែ២មាត្រាទេ គឺមាត្រា ៤៩ ថ្មី (បី) ដែលផ្តល់សិទ្ធិដល់ គ.ជ.ប ក្នុងការបន្ថែម





រយៈពេលពិនិត្យបញ្ជីឈ្មោះ និងចុះឈ្មោះបោះឆ្នោតរហូតដល់ទៅ៣០ថ្ងៃ សម្រាប់ឆ្នាំដែលមានការបោះឆ្នោតសកល(មុនវិសោធនកម្មយើងមានតែ១៥ថ្ងៃទេ) និងមាត្រា ៦៤ ថ្មី (ពីរ) បានបន្ថែមរយៈពេលប្តឹងតវ៉ា ឬ/និង ប្តឹងជំទាស់ទៅនឹងបញ្ជីបោះឆ្នោតដំបូង គឺមានរយៈពេល១០ថ្ងៃ សម្រាប់ឆ្នាំមានការរៀបចំការបោះឆ្នោតជាសកល (កាលពីមុនមានរយៈពេលតែ៥ថ្ងៃប៉ុណ្ណោះ)។



លោកជំទាវ កុយ វ៉េត សមាជិកា គ.ជ.ប







**លើកទី៣**_កិច្ចប្រជុំ ស្តីពីការពិនិត្យបញ្ជីឈ្មោះ និងចុះឈ្មោះបោះឆ្នោត ឆ្នាំ២០១១។ កិច្ចប្រជុំនេះបានប្រព្រឹត្តទៅកាលពីថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០១១ ក្រោមការដឹកនាំដោយ លោកជំទាវ កុយ វ៉េត សមាជិកា គ.ជ.ប ដែលមានការចូលរួមពីតំណាងគណបក្សនយោបាយ អង្គការមិនមែនរដ្ឋាភិបាល និងអ្នកសារព័ត៌មានជាតិ និងអន្តរជាតិប្រមាណ៧០នាក់។ លោកជំទាវបានមានប្រសាសន៍ថា ការពិនិត្យបញ្ជីឈ្មោះ និងចុះឈ្មោះបោះឆ្នោតចាប់ផ្តើមពីថ្ងៃទី០១ ខែកញ្ញា រហូតដល់ថ្ងៃទី១៥ ខែតុលា ឆ្នាំ២០១១ មានរយៈពេល៤៥ថ្ងៃ។ តាមបទបញ្ញា និងនីតិវិធីរបស់ គ.ជ.ប ក្នុងករណីចាំបាច់ ក្រុមប្រឹក្សាឃុំ សង្កាត់អាចចាត់ឱ្យធ្វើការចុះឈ្មោះចល័តនៅតាមឃុំ សង្កាត់ ឬនៅតាមកន្លែងណាមួយដែលសមស្រប ប៉ុន្តែការិយាល័យចុះឈ្មោះដំបូងនៅសាលាឃុំ សង្កាត់ គឺចាប់ពីថ្ងៃទី០១ ដល់ថ្ងៃទី១៥ ខែកញ្ញា បន្ទាប់មកធ្វើការចល័តការិយាល័យទៅតាមភូមិនានា ដែលនៅឆ្ងាយពីសាលាឃុំ សង្កាត់លើសពី៥គីឡូម៉ែត្រ ឬមួយភូមិនានាដែលមានលក្ខណៈស្មុគស្មាញ ប្រជាពលរដ្ឋពិបាកធ្វើដំណើរមកចុះឈ្មោះ។ ការចល័តការិយាល័យ ចាប់ពីថ្ងៃទី១៦ ខែកញ្ញា រហូតដល់ថ្ងៃទី០៧ ខែតុលា បន្ទាប់មកការិយាល័យចល័តមកសាលាឃុំ សង្កាត់វិញចាប់ពីថ្ងៃទី០៨ ដល់ថ្ងៃទី១៥ ខែតុលា។ ដូច្នេះការិយាល័យចុះឈ្មោះបោះឆ្នោតនៅសាលាឃុំ សង្កាត់មានរយៈពេល២៣ថ្ងៃ។

**លើកទី៤**_កិច្ចប្រជុំ ស្តីពីការបោះឆ្នោតឡើងវិញជ្រើសរើសក្រុមប្រឹក្សាខណ្ឌពោធិ៍សែនជ័យ។ កិច្ចប្រជុំនេះបានប្រព្រឹត្តទៅនៅថ្ងៃទី១៣ ខែកញ្ញា ឆ្នាំ២០១១ ក្រោមការដឹកនាំដោយ ឯកឧត្តម ឃ្លោក ប៊ុតឌី សមាជិក គ.ជ.ប ដែលមានការចូលរួមពីតំណាងគណបក្សនយោបាយ អង្គការមិនមែនរដ្ឋាភិបាល និងអ្នកសារព័ត៌មានជាតិ និងអន្តរជាតិប្រមាណ៦៥នាក់។ ឯកឧត្តមបានមានប្រសាសន៍ថា ការបោះឆ្នោតឡើងវិញជ្រើសរើសក្រុមប្រឹក្សាខណ្ឌពោធិ៍សែនជ័យ

# ការពិនិត្យបញ្ជីឈ្មោះ និងចុះឈ្មោះបោះឆ្នោត ឆ្នាំ២០១១



ដែលជាខណ្ឌទើបតែបង្កើតថ្មីនៅក្នុងរាជធានីភ្នំពេញ។ ច្បាប់តម្រូវឱ្យរៀបចំការបោះឆ្នោតនេះរយៈពេលយ៉ាងយូរ២៤០ថ្ងៃ ក្រោយការបង្កើតខណ្ឌថ្មី។ ខណ្ឌថ្មីនេះមានសង្កាត់ចំនួន១៣ អ្នកដែលមានសិទ្ធិបោះឆ្នោតគឺជាសមាជិកក្រុមប្រឹក្សាសង្កាត់ក្នុងមុខតំណែងចំនួន៨៩នាក់ ហើយក្រុមប្រឹក្សាខណ្ឌពោធិ៍សែនជ័យមានអាសនៈចំនួន១៩។ ទីតាំងការិយាល័យបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាខណ្ឌនេះ គឺនៅវិទ្យាល័យហ៊ុនសែនជម្ពូវ័ន្ត រាជធានីភ្នំពេញ។


ឯកឧត្តម ឃ្លោក ប៊ុតឌី សមាជិក គ.ជ.ប







**លើកទី៥**_កិច្ចប្រជុំ ស្តីពីការពិនិត្យបញ្ជីឈ្មោះ និងចុះឈ្មោះបោះឆ្នោត ឆ្នាំ២០១១។ កិច្ចប្រជុំនេះបានប្រព្រឹត្តទៅកាលពីថ្ងៃទី២២ ខែកញ្ញា ឆ្នាំ២០១១ ក្រោមការដឹកនាំដោយ ឯកឧត្តម ហារ៉ាណា ស៊ីរិល័យ សមាជិក គ.ជ.ប និងមានការចូលរួមពីតំណាងគណបក្សនយោបាយ អង្គការមិនមែនរដ្ឋាភិបាល និងអ្នកសារព័ត៌មានជាតិ និងអន្តរជាតិប្រមាណ៧០នាក់។ នៅក្នុងកិច្ចប្រជុំនោះ ឯកឧត្តមបានលើកឡើងពីសភាពការណ៍ទូទៅនៃការពិនិត្យបញ្ជីឈ្មោះ និងចុះឈ្មោះបោះឆ្នោត ឆ្នាំ២០១១។


ឯកឧត្តម ហារ៉ាណា ស៊ីរិល័យ សមាជិក គ.ជ.ប







**លើកទី៦**_កិច្ចប្រជុំ ស្តីពីការបោះឆ្នោតឡើងវិញជ្រើសរើសក្រុមប្រឹក្សាខណ្ឌពោធិ៍សែនជ័យ។ កិច្ចប្រជុំនេះបានប្រព្រឹត្តទៅកាលពីថ្ងៃទី០៤ ខែតុលា ឆ្នាំ២០១១ ក្រោមការដឹកនាំដោយ ឯកឧត្តម មាន សទិ សមាជិក គ.ជ.ប និងមាន





# ការពិនិត្យបញ្ជីឈ្មោះ និងចុះឈ្មោះបោះឆ្នោត ឆ្នាំ២០១១



ឯកឧត្តម មាន សទិ សមាជិក គ.ជ.ប







ការចូលរួមពីតំណាងគណបក្សនយោបាយ អង្គការមិនមែនរដ្ឋាភិបាល និងអ្នកសារព័ត៌មានជាតិ និងអន្តរជាតិប្រមាណ ៦៥នាក់។ ឯកឧត្តមបានមានប្រសាសន៍ថា គ.ជ.ប បានរៀបចំបញ្ជីបោះឆ្នោត ហើយបានធ្វើការបិទផ្សាយនៅសាលាខណ្ឌ សង្កាត់ កាលពីថ្ងៃទី១១ ខែតុលា ឆ្នាំ២០១១ ដើម្បីឱ្យប្រជាពលរដ្ឋគ្រប់រូបធ្វើការប្តឹងតវ៉ា ឬជំទាស់។ ឯកឧត្តមបានបញ្ជាក់ថា ការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាខណ្ឌពោធិ៍សែនជ័យ បណ្តឹងទាក់ទងនឹងបញ្ជីបោះឆ្នោតមានតែ១ ដំណាក់កាលប៉ុណ្ណោះ គឺនៅពេលបិទផ្សាយបញ្ជីដំបូង ហើយបញ្ជីបោះឆ្នោតសម្រាប់ការបោះឆ្នោតនេះនឹងត្រូវផ្តល់សុពលភាពនៅថ្ងៃទី០១ ខែវិច្ឆិកា ឆ្នាំ២០១១។



ឯកឧត្តម ឯម សូផាត សមាជិក គ.ជ.ប







**លើកទី៧**_កិច្ចប្រជុំ ស្តីពីការពិនិត្យបញ្ជីឈ្មោះ និងចុះឈ្មោះបោះឆ្នោត ឆ្នាំ២០១១។ កិច្ចប្រជុំនេះបានប្រព្រឹត្តទៅនៅថ្ងៃទី១៤ ខែតុលា ឆ្នាំ២០១១ ក្រោមការដឹកនាំដោយ ឯកឧត្តម ឯម សូផាត សមាជិក គ.ជ.ប និងមានការចូលរួមពីតំណាងគណបក្សនយោបាយ អង្គការមិនមែនរដ្ឋាភិបាល និងអ្នកសារព័ត៌មានជាតិ និងអន្តរជាតិប្រមាណ៧០នាក់។ ឯកឧត្តមបានលើកឡើងថា ការបិទផ្សាយបញ្ជីបោះឆ្នោតដំបូង គឺដើម្បីឱ្យប្រជាពលរដ្ឋមកពិនិត្យមើលឈ្មោះរបស់ខ្លួនក្នុងករណីមិនត្រឹមត្រូវ ធ្វើការតវ៉ាទៅក្រុមប្រឹក្សាឃុំ សង្កាត់ ឬស្មៀនឱ្យកែតម្រូវឡើងវិញ ហើយប្រជាពលរដ្ឋគ្រប់រូប



អាចធ្វើការប្តឹងតវ៉ាពីការបាត់បង់ឈ្មោះ ឬជំទាស់ការចុះឈ្មោះ ឬរក្សាទុកឈ្មោះ ឬមានឈ្មោះលើសពីមួយក្នុងបញ្ជីបោះឆ្នោត។ តាមនីតិវិធី ការប្តឹងជំទាស់ត្រូវប្តឹងទៅក្រុមប្រឹក្សាឃុំ សង្កាត់ក្នុងរយៈពេល១០ថ្ងៃយ៉ាងយូរ បន្ទាប់ពីថ្ងៃបិទផ្សាយបញ្ជីបោះឆ្នោតដំបូង។ ក្រុមប្រឹក្សាឃុំ សង្កាត់ត្រូវប្រជុំសម្រេចក្នុងរយៈពេល៣ថ្ងៃយ៉ាងយូរ បន្ទាប់ពីទទួលពាក្យបណ្តឹង។ ករណីអ្នកប្តឹងមិនយល់ព្រមតាមការសម្រេចរបស់ក្រុមប្រឹក្សាឃុំ សង្កាត់ ត្រូវប្តឹងទៅ គ.ជ.ប រយៈពេល៥ថ្ងៃយ៉ាងយូរបន្ទាប់ពីការសម្រេចនោះ។ ហើយ គ.ជ.ប ដោះស្រាយរយៈពេល៥ថ្ងៃបន្ទាប់ពីទទួលបណ្តឹង។ ករណីមិនយល់ព្រមតាមការសម្រេចរបស់ គ.ជ.ប អ្នកប្តឹងត្រូវប្តឹងទៅក្រុមប្រឹក្សាធម្មនុញ្ញក្នុងរយៈពេល៥ថ្ងៃ បន្ទាប់ពី គ.ជ.ប សម្រេច។ ក្រុមប្រឹក្សាធម្មនុញ្ញដោះស្រាយក្នុងរយៈពេល១០ថ្ងៃ បន្ទាប់ពីទទួលបណ្តឹង។ ការសម្រេចរបស់ក្រុមប្រឹក្សាធម្មនុញ្ញជាការសម្រេចចុងក្រោយ និងបិទផ្លូវតវ៉ា។



*ឯកឧត្តម សោម ច័ន្ទឌីណា សមាជិក គ.ជ.ប*







**លើកទី៨**_កិច្ចប្រជុំ ស្តីពីការបោះឆ្នោតជ្រើសតាំងសមាជិកព្រឹទ្ធសភា នីតិកាលទី៣។ កិច្ចប្រជុំនេះបានប្រព្រឹត្តទៅនៅថ្ងៃទី២៤ ខែតុលា ឆ្នាំ២០១១ ក្រោមការដឹកនាំដោយ ឯកឧត្តម សោម ច័ន្ទឌីណា សមាជិក គ.ជ.ប ដែលមានតំណាងគណបក្សនយោបាយ អង្គការមិនមែនរដ្ឋាភិបាល និងអ្នកសារព័ត៌មានជាតិ និងអន្តរជាតិចូលរួមប្រមាណ៦០នាក់។ កិច្ចប្រជុំនេះផ្តោតសំខាន់លើការបិទផ្សាយបញ្ជីទីតាំងការិយាល័យចុះឈ្មោះបោះឆ្នោត និងការិយាល័យបោះឆ្នោត ការចុះបញ្ជីគណបក្សនយោបាយឈរឈ្មោះបោះឆ្នោត និងបេក្ខជនឈរឈ្មោះ និងការចុះឈ្មោះអ្នកសង្កេតការណ៍ជាតិ និងអន្តរជាតិ។ ឯកឧត្តម សោម ច័ន្ទឌីណា បានមានប្រសាសន៍ថា ការបោះឆ្នោតជ្រើសតាំងសមាជិកព្រឹទ្ធសភាសម្រាប់នីតិកាលទី៣ ប្រព្រឹត្តទៅនៅថ្ងៃទី២៩ ខែមករា ឆ្នាំ២០១២។ ហើយអាសនៈទាំងអស់មានចំនួន៦១។ តាមច្បាប់សមាជិកព្រឹទ្ធសភាចំនួន២រូប ត្រូវបានចាត់តាំងដោយព្រះមហាក្សត្រ ចំនួន២រូប ត្រូវបានរដ្ឋសភាជ្រើសតាំងដោយមតិភាគច្រើនដោយប្រៀប និងចំនួន៥៧រូបទៀតត្រូវបោះឆ្នោតជ្រើសតាំងដោយសមាជិករដ្ឋសភា និងក្រុមប្រឹក្សាឃុំ សង្កាត់ក្នុងតំណែងសរុបចំនួន**១១.៤៧៦**នាក់។ ឯកឧត្តមបានបន្ថែមថា ការបោះឆ្នោតជ្រើសតាំងសមាជិកព្រឹទ្ធសភាជាការបោះឆ្នោតអសកល ហើយត្រូវធ្វើឡើងរៀងរាល់៦ឆ្នាំម្តង។ ការិយាល័យបោះឆ្នោតត្រូវបានកំណត់តាមរាជធានី





# ការពិនិត្យបញ្ជីឈ្មោះ និងចុះឈ្មោះបោះឆ្នោត ឆ្នាំ២០១១



ឯកឧត្តម ម៉ៅ សុភារិទ្ធ សមាជិក គ.ជ.ប

ខេត្តចំណុះភូមិភាគ ដែលមានចំនួនសរុប៣៣ការិយាល័យ។

*កិច្ចប្រជុំ-សន្និសីទសារព័ត៌មាននេះនៅសល់ចំនួន ១១លើកទៀត នឹងប្រព្រឹត្តទៅតាមកម្មវិធីដូចខាងក្រោម ៖*

**លើកទី៩**-សន្និសីទសារព័ត៌មាន ស្តីពីការបោះឆ្នោតជ្រើសតាំងសមាជិកព្រឹទ្ធសភា នីតិកាលទី៣។ សន្និសីទនេះនឹងប្រព្រឹត្តទៅនៅថ្ងៃទី០៤ ខែវិច្ឆិកា ឆ្នាំ២០១១ ក្រោមការដឹកនាំដោយ ឯកឧត្តម ម៉ៅ សុភារិទ្ធ សមាជិក គ.ជ.ប។ ប្រធានបទបង្ហាញពីលទ្ធផលបណ្តោះអាសន្ននៃការចុះបញ្ជីគណបក្សនយោបាយ និងបញ្ជីបេក្ខជនឈរឈ្មោះ និងការស្រង់ឈ្មោះអ្នកបោះឆ្នោត សម្រាប់ការបោះឆ្នោតជ្រើសតាំងសមាជិកព្រឹទ្ធសភា នីតិកាលទី៣។

**លើកទី១០**-កិច្ចប្រជុំ ស្តីពីការបោះឆ្នោតឡើងវិញជ្រើសរើសក្រុមប្រឹក្សាខណ្ឌពោធិ៍សែនជ័យ។ កិច្ចប្រជុំនេះនឹងប្រព្រឹត្តទៅនៅថ្ងៃទី១៥ ខែវិច្ឆិកា ឆ្នាំ២០១១ ក្រោមអធិបតីភាព ឯកឧត្តម អ៊ឹម សូស្ឌី ប្រធាន គ.ជ.ប។ កិច្ចប្រជុំនេះផ្តោតសំខាន់លើការបិទផ្សាយបញ្ជីឈ្មោះទីតាំងការិយាល័យបោះឆ្នោតនៅសាលាសង្កាត់ និងទីសាធារណៈក្នុងមណ្ឌល ការបិទផ្សាយបញ្ជីបោះឆ្នោតផ្លូវការនៅការិយាល័យបោះឆ្នោត និងការឃោសនាបោះឆ្នោត។

**លើកទី១១**-សន្និសីទសារព័ត៌មាន ស្តីពីការពិនិត្យបញ្ជីឈ្មោះ និងចុះឈ្មោះបោះឆ្នោត។ សន្និសីទនេះនឹងប្រព្រឹត្តនៅថ្ងៃទី២២ ខែវិច្ឆិកា ឆ្នាំ២០១១ ក្រោមអធិបតីភាព លោកជំទាវបណ្ឌិត ស៊ីន ជុំបូ អនុប្រធាន គ.ជ.ប។ សន្និសីទនេះបង្ហាញពីបណ្តឹងសរុបក្នុងអំឡុងពេលបិទផ្សាយបញ្ជីបោះឆ្នោតដំបូង លទ្ធផលបណ្តោះអាសន្ន និងការបញ្ចូលទិន្នន័យនៅមជ្ឈមណ្ឌលកុំព្យូទ័រ។

**លើកទី១២**-កិច្ចប្រជុំ ស្តីពីការបោះឆ្នោតជ្រើសតាំងសមាជិកព្រឹទ្ធសភា នីតិកាលទី៣។ កិច្ចប្រជុំនេះនឹងប្រព្រឹត្តទៅនៅថ្ងៃទី០១ ខែធ្នូ ឆ្នាំ២០១១ ក្រោមការដឹកនាំដោយ លោកជំទាវ កុយ វ៉េត សមាជិកា គ.ជ.ប។ កិច្ចប្រជុំនេះផ្តោតលើការបិទផ្សាយបញ្ជីបោះឆ្នោតដំបូង ការប្តឹងតវ៉ា ឬប្តឹងជំទាស់លើបញ្ជីបោះឆ្នោតដំបូង និងបញ្ជីគណបក្សនយោបាយឈរឈ្មោះបោះឆ្នោត និងបេក្ខជនឈរឈ្មោះ។

**លើកទី១៣**-សន្និសីទសារព័ត៌មាន ស្តីពីការបោះឆ្នោតឡើងវិញជ្រើសរើសក្រុមប្រឹក្សាខណ្ឌពោធិ៍សែនជ័យ។ សន្និសីទនេះនឹងប្រព្រឹត្តនៅថ្ងៃទី១១ ខែធ្នូ ឆ្នាំ២០១១ ក្រោមការដឹកនាំដោយ ឯកឧត្តម ឃ្លោក ប៊ុតឌី សមាជិក គ.ជ.ប។ សន្និសីទនេះ ឯកឧត្តម ឃ្លោក ប៊ុតឌី នឹងមានប្រសាសន៍អំពីព្រឹត្តិការណ៍នៃការឃោសនាបោះឆ្នោត ការបោះឆ្នោត និងប្រកាសលទ្ធផលបឋមនៃការបោះឆ្នោត។

**លើកទី១៤**-សន្និសីទសារព័ត៌មាន ស្តីពីការបោះឆ្នោតឡើងវិញជ្រើសរើសក្រុមប្រឹក្សាខណ្ឌ តទៅទំព័រទី 11



# ចំនួនអ្នកសង្កេតការណ៍ និងតំណាងគណបក្សនយោបាយដែលចូលរួម សង្កេតមើលនៅក្នុងដំណើរការពិនិត្យបញ្ជីឈ្មោះ និងចុះឈ្មោះបោះឆ្នោត

ដើម្បីឱ្យការបោះឆ្នោតមួយប្រព្រឹត្តទៅប្រកបដោយលក្ខណៈប្រជាធិបតេយ្យ សេរី និងត្រឹមត្រូវ ការចូលរួមតាមតួនាទីពីគណបក្សនយោបាយ អង្គការមិនមែនរដ្ឋាភិបាលជាតិ និងអន្តរជាតិ និងប្រព័ន្ធផ្សព្វផ្សាយព័ត៌មាន គឺជាចំណែកមួយយ៉ាងសំខាន់។ ដូច្នេះហើយ បានជាច្បាប់បោះឆ្នោតក៏ដូចជាបទបញ្ជា និងនីតិវិធី គ.ជ.ប បានបើកចំហរឱ្យមានការចូលរួមពីស្ថាប័នពាក់ព័ន្ធទាំងអស់នោះ។

គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត (គ.ជ.ប) បានទទួលស្គាល់អង្គការសង្កេតការណ៍បោះឆ្នោតជាតិ និងអន្តរជាតិចំនួន១១(អន្តរជាតិចំនួន២) បន្ទាប់ពីអង្គការទាំងនោះបានដាក់ពាក្យស្នើសុំអ្នកសង្កេតការណ៍មក គ.ជ.ប។ អង្គការទាំងនោះបានដាក់ពង្រាយអ្នកសង្កេតការណ៍សរុបចំនួន១.៣៩៧នាក់ ដែលក្នុងនោះអ្នកសង្កេតការណ៍ជាតិ១.៣៧៧នាក់ មានស្រី ៥៣៨នាក់ និងចល័ត៤៣នាក់ និងអ្នកសង្កេតការណ៍អន្តរជាតិចំនួន២០នាក់ ក្នុងនោះមានស្រី១២នាក់ ដើម្បីចូលរួមសង្កេតមើលដំណើរការពិនិត្យបញ្ជីឈ្មោះ និងចុះឈ្មោះបោះឆ្នោត ឆ្នាំ២០១១ ការបោះឆ្នោតឡើងវិញជ្រើសរើសក្រុមប្រឹក្សាខណ្ឌពោធិ៍សែនជ័យនៃរាជធានីភ្នំពេញ ឆ្នាំ២០១១ ការបោះឆ្នោតជ្រើសតាំងសមាជិកព្រឹទ្ធសភា នីតិកាលទី៣ ឆ្នាំ២០១២ និងការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ អាណត្តិទី៣ ឆ្នាំ២០១២ ខាងមុខនេះ។

អង្គការមិនមែនរដ្ឋាភិបាលជាតិ និងអន្តរជាតិដែល គ.ជ.ប ទទួលស្គាល់រួមមាន ៖



*កិច្ចប្រជុំកាលពីថ្ងៃទី២៤ ខែតុលា នៅទីស្តីការ គ.ជ.ប*

### *អង្គការសង្កេតការណ៍ជាតិ*

១-ក្រុមប្រឹក្សាយុវជនកម្ពុជា(YCC) ចំនួនអ្នកសង្កេតការណ៍សរុប២៩៤នាក់ ស្រី១៤០នាក់ និងចល័ត៥នាក់។

២-គណៈកម្មាធិការដើម្បីការបោះឆ្នោតដោយសេរី និងយុត្តិធម៌នៅកម្ពុជា(COMFREL) មានអ្នកសង្កេតការណ៍សរុបចំនួន៣០០នាក់ ស្រី៦៧នាក់ និងចល័ត៩នាក់។

៣-គណៈកម្មាធិការអព្យាក្រឹត និងយុត្តិធម៌ ដើម្បីការបោះឆ្នោតដោយសេរី និងត្រឹមត្រូវនៅកម្ពុជា(NICFEC) បានដាក់អ្នកសង្កេតការណ៍សរុប៣២០នាក់ ស្រី១១៣នាក់ និងចល័ត៥នាក់។

៤-អង្គការលើកស្ទួយសុខមាលភាពជនក្រីក្រ(IHPPO) មានអ្នកសង្កេតការណ៍សរុបចំនួន២៣ នាក់ស្រី៧នាក់ និងចល័ត៣នាក់។





៥_អង្គការសុខភាពផ្លូវចិត្តបែបបុរាណ និងសម័យ (IMMHO) មានអ្នកសង្កេតការណ៍សរុប៣០នាក់ ស្រី ១នាក់ និងចល័ត៥នាក់។

៦_អង្គការគ្រួសារអភិវឌ្ឍន៍កសិកម្ម(FADC) មានអ្នកសង្កេតការណ៍សរុប៤០នាក់ ស្រី១៤នាក់ និងចល័ត២នាក់។

៧_អង្គការស្ត្រីសម្រាប់អភិវឌ្ឍន៍សិទ្ធិមនុស្ស ឧស្សាហកម្ម កសិកម្ម(MAHIAD) មានអ្នកសង្កេតការណ៍សរុបចំនួន ២៧នាក់ ស្រី១២នាក់ និងចល័ត៣នាក់។

៨_អង្គការប្រជាធិបតេយ្យ និងសិទ្ធមនុស្សក្នុងប្រតិបត្តិការ (DHRAC) បានដាក់អ្នកសង្កេតការណ៍សរុបចំនួន ២៨៩នាក់ ស្រី១៦៨នាក់ និងចល័ត៥នាក់។

៩_អង្គការសេវាប្រជាធិបតេយ្យ(DSO) មានអ្នកសង្កេតការណ៍សរុប៥៤នាក់ ស្រី១៦នាក់ និងចល័ត៦នាក់។

### *អង្គការសង្កេតការណ៍អន្តរជាតិ*



*អ្នកសង្កេតការណ៍បោះឆ្នោតរបស់អង្គការ NDI ចូលរួមក្នុងកិច្ចប្រជុំ កាលពីថ្ងៃទី១៣ ខែកញ្ញា នៅទីស្តីការ គ.ជ.ប*

១០_វិទ្យាស្ថានជាតិប្រជាធិបតេយ្យ(NDI) មានអ្នកសង្កេតការណ៍សរុប១៤នាក់ ស្រី៨នាក់។

១១_មូលនិធិអន្តរជាតិសម្រាប់ប្រព័ន្ធបោះឆ្នោត(IFES) មានអ្នកសង្កេតការណ៍សរុប៦នាក់ ស្រី៤នាក់។

ដោយឡែក មានគណបក្សនយោបាយចំនួន៦ បានដាក់តំណាងរបស់ខ្លួនសរុប១០.០៩១នាក់ ស្ត្រី ៧៤២នាក់ ក្នុងនោះពេញសិទ្ធិចំនួន៥.២៤៨នាក់ ស្ត្រី ៣៣២នាក់ និងបម្រុងចំនួន៤.៨៤៣នាក់ ស្ត្រី៤១០នាក់ ចូលរួមសង្កេតការណ៍ក្នុងដំណើរការពិនិត្យបញ្ជីឈ្មោះ និងចុះឈ្មោះបោះឆ្នោតឆ្នាំ២០១១ រួមមាន ៖



*តំណាងគណបក្សនយោបាយចូលរួមក្នុងកិច្ចប្រជុំ*

**១**_គណបក្សប្រជាជនកម្ពុជា មានតំណាងពេញសិទ្ធិចំនួន១.៥៩៦នាក់ ស្ត្រី១០៩នាក់ និងបម្រុង១.៤៩៨នាក់ ស្ត្រី១៥១នាក់។

**២**_គណបក្សសម រង្ស៊ី មានតំណាងពេញសិទ្ធិចំនួន ១.៤០៧នាក់ ស្ត្រី១១៤នាក់ និងបម្រុង១.២៦២នាក់ ស្ត្រី១១៤នាក់។

**៣**_គណបក្សហ្វ៊ុនស៊ិនប៉ិច មានតំណាងពេញសិទ្ធិចំនួន ១.៣៧១នាក់ ស្ត្រី៨៩នាក់ និងបម្រុង១.២៥៣នាក់ ស្ត្រី១១១នាក់។

**៤**_គណបក្សសិទ្ធិមនុស្ស មានតំណាងពេញសិទ្ធិចំនួន ៧១៦នាក់ ស្ត្រី១៦នាក់ និងបម្រុង៦៩៣នាក់ ស្ត្រី២៨នាក់។

**៥**_គណបក្សនរោត្តមរណឫទ្ធិ មានតំណាងពេញសិទ្ធិ



ចំនួន១៥១នាក់ ស្ត្រី៤នាក់ និងបម្រុង១៣១នាក់ ស្ត្រី៦នាក់។

**៦**-គណបក្សសញ្ញាតិកម្ពុជា មានតំណាងពេញសិទ្ធិចំនួន ៧នាក់ និងបម្រុង៦នាក់។

យោងតាមបទបញ្ញា និងនីតិវិធីរបស់ គ.ជ.ប កាលបរិច្ឆេទនៃការដាក់ពាក្យសុំចុះឈ្មោះអ្នកសង្កេតការណ៍ជាតិ និងអន្តរជាតិមានដូចខាងក្រោម ៖



*កាលពីថ្ងៃទី២៤ ខែតុលា នៅទីស្តីការ គ.ជ.ប*

-អ្នកសង្កេតការណ៍ជាតិដាក់ពាក្យសុំចាប់ពីថ្ងៃទី១៧ ខែសីហា ឆ្នាំ២០១១ រហូតដល់ថ្ងៃទី២៧ ខែឧសភា ឆ្នាំ២០១២។

-អ្នកសង្កេតការណ៍អន្តរជាតិដាក់ពាក្យសុំចាប់ពីថ្ងៃទី១៧ ខែសីហា ឆ្នាំ២០១១ រហូតដល់ថ្ងៃទី៣ ខែមិថុនា ឆ្នាំ២០១២។

អ្នកសង្កេតការណ៍ជាតិ និងអន្តរជាតិអាចប្រើប្រាស់ប័ណ្ណអ្នកសង្កេតការណ៍ចេញដោយ គ.ជ.ប ដើម្បីសង្កេតមើលដំណើរការពិនិត្យបញ្ជីឈ្មោះ និងចុះឈ្មោះបោះឆ្នោតឆ្នាំ២០១១ ការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាខណ្ឌពោធិ៍សែនជ័យនៃរាជធានីភ្នំពេញ ឆ្នាំ២០១១ ការបោះឆ្នោតជ្រើសតាំងសមាជិកព្រឹទ្ធសភា នីតិកាលទី៣ ឆ្នាំ២០១២ និងការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ អាណត្តិទី៣ ឆ្នាំ២០១២ ដោយមិនតម្រូវឱ្យស្នើសុំម្តងទៀតឡើយ៕



*ភ្នាក់ងារសង្កេតការណ៍បោះឆ្នោតរបស់គណបក្សនយោបាយ*



តមកពីទំព័រទី 8 ***ការផ្សព្វផ្សាយការងាររៀបចំ...***

ពោធិ៍សែនជ័យ។ សន្និសីទនេះនឹងប្រព្រឹត្តនៅថ្ងៃទី២៣ ខែធ្នូ ឆ្នាំ២០១១ ក្រោមការដឹកនាំដោយ ឯកឧត្តម ហាំ៉ណ ស៊ីរិល័យ សមាជិក គ.ជ.ប។ សន្និសីទនេះផ្តោតសំខាន់លើការប្រកាសលទ្ធផលផ្លូវការនៃការបោះឆ្នោតឡើងវិញជ្រើសរើសក្រុមប្រឹក្សាខណ្ឌពោធិ៍សែនជ័យ។

តទៅទំព័រទី 14





# ជំនួបពិភាក្សារវាង គ.ជ.ប ជាមួយតំណាង UNDP ទាក់ទងនឹងការងារបោះឆ្នោតនៅកម្ពុជា

កាលពីព្រឹកថ្ងៃទី២៥ ខែតុលា ឆ្នាំ២០១១ វេលាម៉ោង៩:០០នាទី ឯកឧត្តម អ៊ឹម សួស្ដី ប្រធានគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត(គ.ជ.ប) បានអនុញ្ញាតឱ្យលោកស្រី Elena Tischenko ប្រធានអង្គការ UNDP ប្រចាំប្រទេសកម្ពុជា និងលោក Jairo VALVERDE BERMUDEZ មន្ត្រីទំនាក់ទំនងគណបក្សនយោបាយ ពង្រឹងលទ្ធិប្រជាធិបតេយ្យ និងការបោះឆ្នោតរបស់អង្គការ UNDP ចូលជួបពិភាក្សាជុំវិញការងាររៀបចំការបោះឆ្នោតនៅកម្ពុជា។



*ឯកឧត្តម អ៊ឹម សួស្ដី ប្រធាន គ.ជ.ប ជួបពិភាក្សាជាមួយលោកស្រី Elena Tischenko និងលោក Jairo VALVERDE BERMUDEZ*

ឯកឧត្តម អ៊ឹម សួស្ដី បានជម្រាបជូនភ្ញៀវថា ការងារចំពោះមុខរបស់ គ.ជ.ប គឺត្រូវរៀបចំការងារបោះឆ្នោតចំនួន៤ជាប់ៗគ្នា ទី១ គឺការពិនិត្យបញ្ជីឈ្មោះ និងចុះឈ្មោះបោះឆ្នោតឆ្នាំ២០១១ ទី២ ការបោះឆ្នោតឡើងវិញជ្រើសរើសក្រុមប្រឹក្សាខណ្ឌពោធិ៍សែនជ័យនៃរាជធានីភ្នំពេញ ឆ្នាំ២០១១ ទី៣ ការបោះឆ្នោតជ្រើសតាំងសមាជិកព្រឹទ្ធសភា នីតិកាលទី៣ ឆ្នាំ២០១២ និងទី៤ ការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ អាណត្តិទី៣ ឆ្នាំ២០១២។

ឯកឧត្តមបានបន្ថែមទៀតថា ការពិនិត្យបញ្ជីឈ្មោះ និងចុះឈ្មោះបោះឆ្នោតបានបញ្ចប់ហើយ។ គ.ជ.ប កំពុងបិទផ្សាយបញ្ជីដំបូងនៅតាមសាលាឃុំ សង្កាត់ និងទីប្រជុំជនណាមួយក្នុងឃុំ សង្កាត់ ដើម្បីឱ្យអ្នកបោះឆ្នោតធ្វើការប្ដឹងតវ៉ា ឬប្ដឹងជំទាស់ទៅលើបញ្ជីនេះ ហើយបន្ទាប់ពីដោះស្រាយបណ្ដឹងចប់ គ.ជ.ប ផ្ដល់សុពលភាពលើបញ្ជីបោះឆ្នោតនៅថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១១។ ជាមួយគ្នានេះដែរ គ.ជ.ប កំពុងតែបន្តការងាររៀបចំការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាខណ្ឌពោធិ៍សែនជ័យ និងការបោះឆ្នោតជ្រើសតាំងសមាជិកព្រឹទ្ធសភា។

ទាក់ទងនឹងជំនួបពិភាក្សានេះផងដែរ ឯកឧត្តម អ៊ឹម សួស្ដី ប្រធាន គ.ជ.ប បានឱ្យដឹងថា នៅថ្ងៃខាងមុខ UNDP នឹងបញ្ជូនគណៈប្រតិភូ២ក្រុមមកពីញូយ៉ក ដើម្បីធ្វើការវាយតម្លៃពីការវិវឌ្ឍន៍នៅក្នុងប្រទេសកម្ពុជា ដែលគណៈប្រតិភូទី១ វាយតម្លៃទៅលើការវិវឌ្ឍន៍លទ្ធិប្រជាធិបតេយ្យនៅកម្ពុជា និងគណៈប្រតិភូទី២ វាយតម្លៃជុំវិញការគាំទ្ររបស់ UNDP ទៅលើដំណើរការបោះឆ្នោតនៅកម្ពុជា៕



# អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរដែលផុតកំណត់ត្រូវបានបន្តសុពលភាព រហូតដល់ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៣



ឯកឧត្តម ទេព នីថា អគ្គលេខាធិការ គ.ជ.ប នៅក្នុងស្ទូឌីយោទូរទស្សន៍បាយ័ន

អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរដែលជាឯកសារគោលដ៏សំខាន់មួយសម្រាប់ប្រជាពលរដ្ឋខ្មែរក្នុងការប្រើប្រាស់ធ្វើជាឯកសារផ្សេងៗ ក្នុងនោះមានទាំងសម្រាប់ការចុះឈ្មោះបោះឆ្នោត និងការបោះឆ្នោត ត្រូវបានរាជរដ្ឋាភិបាលចេញអនុក្រឹត្យសម្រេចឱ្យបន្តសុពលភាពរហូតដល់ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៣។

តាមខ្លឹមសារអនុក្រឹត្យលេខ១៣២អនក្រ.បក ស្តីពីការផ្តល់អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរទុតិយតា ចុះថ្ងៃទី២៣ ខែមិថុនា ឆ្នាំ២០១១ បានឱ្យដឹងថា ប្រជាពលរដ្ឋដែលកំពុងប្រើប្រាស់អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរអស់សុពលភាព ត្រូវមកបំពេញបែបបទសុំធ្វើអត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរទុតិយតានៅប៉ុស្តិ៍នគរបាលរដ្ឋបាលឃុំ សង្កាត់ដែលខ្លួនតាំងទីលំនៅអចិន្ត្រៃយ៍។ រីឯអត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរដែលអស់សុពលភាព ហើយអ្នកប្រើប្រាស់មិនទាន់បានបំពេញបែបបទសុំធ្វើអត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរទុតិយតា ត្រូវបានបន្តសុពលភាពរហូតដល់ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៣។

ទាក់ទងនឹងអត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរអស់សុពលភាពនេះដែរ គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត (គ.ជ.ប) បានផ្សព្វផ្សាយយ៉ាងទូលំទូលាយតាមរយៈស្ប៉ត វីដេអូ ស្ប៉តវិទ្យុ សេចក្តីជូនដំណឹង សេចក្តីប្រកាសព័ត៌មាន តាំងពីដើមខែសីហា ឆ្នាំ២០១១ ដើម្បីឱ្យប្រជាពលរដ្ឋបានជ្រួតជ្រាប និងប្រើប្រាស់ឯកសារនេះធ្វើជាឯកសារដើម្បីចុះឈ្មោះបោះឆ្នោត និងបោះឆ្នោត។ បន្ថែមពីលើនេះទៀត ឯកឧត្តម ទេព នីថា អគ្គលេខាធិការ គ.ជ.ប ក៏បានផ្សព្វផ្សាយ និងពន្យល់យ៉ាងពិស្តារកាលពីថ្ងៃទី១២ ខែតុលា ឆ្នាំ២០១១ នៅក្នុងកម្មវិធីកិច្ចពិភាក្សាពិសេសរបស់ទូរទស្សន៍បាយ័នដែលមានខ្លឹមសារដូចខាងក្រោម ៖

បញ្ហាអត្តសញ្ញាណ ជាអនុសាសន៍មួយដែលបានលើកឡើងដោយអ្នកសង្កេតការណ៍ជាតិ និងអន្តរជាតិ តាំងពីក្រោយការបោះឆ្នោតឆ្នាំ២០០៨ ហើយ គ.ជ.ប បានសហការជាមួយក្រសួងមហាផ្ទៃធ្វើការស្រាវជ្រាវពីបញ្ហានេះ ទី១ ប្រធានបទសំខាន់ទាក់ទងការចុះឈ្មោះបោះឆ្នោត ទី២ ទាក់ទងនឹងអត្តសញ្ញាណសម្រាប់បម្រើឱ្យការបោះឆ្នោតនេះ។ ហើយយើងឃើញបញ្ហាពីរទាក់ទងនឹងបញ្ហាអត្តសញ្ញាណនេះ។ ទី១ ការប្រើប្រាស់ទម្រង់ ១០១៨ ពីមុនមកគឺមិនសូវបានល្អ។ ទី២ គឺឯកសារបញ្ជាក់អត្តសញ្ញាណសញ្ជាតិខ្មែរមួយចំនួនហួសសុពលភាពសម្រាប់ឆ្នាំបោះឆ្នោត២០១១_២០១២ រហូតដល់២០១៣នេះ។ អញ្ចឹងហើយក្រុមការងារបច្ចេកទេសនេះបានស្នើដោះស្រាយបញ្ហា២៖ **ទី១** ដូរឯកសារទម្រង់១០១៨ចេញរៀបចំទម្រង់ថ្មីដែលមានគណនេយ្យភាព មានការត្រួតពិនិត្យ



# ការពិនិត្យបញ្ជីឈ្មោះ និងចុះឈ្មោះបោះឆ្នោត ឆ្នាំ២០១១

ត្រឹមត្រូវ មិនក្លែងបន្លំបាន ដើម្បីធ្វើយ៉ាងណាឱ្យប្រជាពលរដ្ឋអាចប្រើប្រាស់ជាឯកសារចុះឈ្មោះបោះឆ្នោត ឬបោះឆ្នោតបាន។ ដូចយើងដឹងហើយថា ប្រជាពលរដ្ឋយើងទូទាំងប្រទេសពុំមានអត្តសញ្ញាណប័ណ្ណទាំងអស់គ្នាទេ ហើយម្យ៉ាងទៀតក៏មានប្រជាពលរដ្ឋមួយចំនួនបានបាត់អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ អញ្ចឹងយើងចាំបាច់ត្រូវមានឯកសារជំនួស ដើម្បីឱ្យគាត់អនុវត្តសិទ្ធិបោះឆ្នោតរបស់គាត់បាន ហើយការងារនេះបានត្រូវដោះស្រាយរួចហើយ។ **ទី២** អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរដែលហួសសុពលភាពអាចប្រើក្នុងការងារបោះឆ្នោតចាប់តាំងពីថ្ងៃនេះទៅ រហូតដល់ចប់ឆ្នាំ២០១៣។ គ.ជ.ប បានផ្សព្វផ្សាយបញ្ហានេះទូលំទូលាយណាស់ដល់ប្រជាពលរដ្ឋ មានការផ្សព្វផ្សាយតាមរយៈស្ប៉ូតវិទ្យុ ស្ប៉ូតវីដេអូ ខិត្តប័ណ្ណ ហើយក៏ដូចជាក្រុមប្រឹក្សាឃុំសង្កាត់ធ្វើការផ្សព្វផ្សាយតាមឃុំ សង្កាត់តែម្តង។

តាមតួលេខដែលបានលើកឡើងនៅពេលធ្វើសិក្ខាសាលានោះ អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរហួសសុពលភាពគិតរហូតដល់ឆ្នាំ២០១៣ មាន៤លានសន្លឹក ហើយក្នុងនោះលទ្ធភាពរបស់ក្រសួងអាចចេញថ្មីក្នុងមួយឆ្នាំបានជិត១លានសន្លឹក ហើយបើយើងគិតទៅនៅសល់ជាង១លានសន្លឹកដែលមិនអាចធ្វើទាន់ អញ្ចឹងការដោះស្រាយរបស់រាជរដ្ឋាភិបាលដោយចេញអនុក្រឹត្យឱ្យបន្តសុពលភាពរហូតដល់ឆ្នាំ២០១៣ គឺវាអាចដោះស្រាយបញ្ហានេះបានទាំងអស់៕

---

*តមកពីទំព័រទី 11* ***ការផ្សព្វផ្សាយការរៀបចំ...***

**លើកទី១៥**_ កិច្ចប្រជុំ ស្តីពីការបោះឆ្នោតជ្រើសតាំងសមាជិកព្រឹទ្ធសភា នីតិកាលទី៣។ កិច្ចប្រជុំនេះនឹងប្រព្រឹត្តទៅនៅថ្ងៃទី២៨ ខែធ្នូ ឆ្នាំ២០១១ ក្រោមការដឹកនាំដោយ ឯកឧត្តម មាន សទិ សមាជិក គ.ជ.ប។ កិច្ចប្រជុំលើកអំពីការបិទផ្សាយបញ្ជីគណបក្សនយោបាយឈរឈ្មោះបោះឆ្នោត និងបញ្ជីបេក្ខជនឈរឈ្មោះបោះឆ្នោត និងការឃោសនាបោះឆ្នោត។

**លើកទី១៦**_ សន្និសីទសារព័ត៌មាន ស្តីពីការពិនិត្យបញ្ជីឈ្មោះ និងចុះឈ្មោះបោះឆ្នោត។ សន្និសីទនេះនឹងប្រព្រឹត្តទៅនៅថ្ងៃទី០៤ ខែមករា ឆ្នាំ២០១២ ក្រោមការដឹកនាំដោយ ឯកឧត្តម ឯម សូផាត សមាជិក គ.ជ.ប។ សន្និសីទនេះប្រកាសផ្សាយពីបញ្ជីបោះឆ្នោតផ្លូវការឆ្នាំ២០១១។

**លើកទី១៧**_ កិច្ចប្រជុំ ស្តីពីការបោះឆ្នោតជ្រើសតាំងសមាជិកព្រឹទ្ធសភា នីតិកាលទី៣។ កិច្ចប្រជុំនេះនឹងប្រព្រឹត្តទៅនៅថ្ងៃទី១៣ ខែមករា ឆ្នាំ២០១២ ក្រោមកាដឹកនាំដោយ ឯកឧត្តម សោម ច័ន្ទឌីណា សមាជិក គ.ជ.ប។ កិច្ចប្រជុំផ្តោតសំខាន់លើការផ្តល់សុពលភាពលើបញ្ជីបោះឆ្នោត និងសភាពការណ៍ទូទៅនៃការឃោសនាបោះឆ្នោត។

**លើកទី១៨**_ សន្និសីទសារព័ត៌មាន ស្តីពីការបោះឆ្នោតជ្រើសតាំងសមាជិកព្រឹទ្ធសភា នីតិកាលទី៣។ សន្និសីទនេះនឹងប្រព្រឹត្តទៅនៅថ្ងៃទី២៧ ខែមករា ឆ្នាំ២០១២ ក្រោមការដឹកនាំដោយ ឯកឧត្តម ម៉ៅ សុភារិទ្ធ សមាជិក គ.ជ.ប។ សន្និសីទនេះបង្ហាញពីព្រឹត្តិការណ៍ទូទៅនៃការឃោសនាបោះឆ្នោត។

**លើកទី១៩**_ សន្និសីទសារព័ត៌មាន ស្តីពីការបោះឆ្នោតជ្រើសតាំងសមាជិកព្រឹទ្ធសភា នីតិកាលទី៣។ សន្និសីទនេះនឹងប្រព្រឹត្តនៅថ្ងៃទី២៩ ខែមករា ឆ្នាំ២០១២ ក្រោមអធិបតីភាព ឯកឧត្តម អ៊ឹម សួស្តី ប្រធាន គ.ជ.ប។ សន្និសីទនេះនិយាយអំពីដំណើរការប្រព្រឹត្តទៅនៃការបោះឆ្នោត និងប្រកាសលទ្ធផលបឋមនៃការបោះឆ្នោត៕



# ឯកឧត្តម អ៊ឹម សួស្តី ប្រធាន គ.ជ.ប បានធ្វើជាអធិបតីក្នុងពិធីផ្សព្វផ្សាយច្បាប់បោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ និងច្បាប់ស្តីពីវិសោធនកម្មនៃច្បាប់នេះ នៅសាលារាជធានីភ្នំពេញ




*ឯឧត្តម អ៊ឹម សួស្តី ប្រធាន គ.ជ.ប ( រូបកណ្តាល )*

កាលពីថ្ងៃទី២៣ ខែសីហា ឆ្នាំ២០១១ ឯកឧត្តម អ៊ឹម សួស្តី ប្រធាន គ.ជ.ប បានធ្វើជាអធិបតីភាពក្នុងពិធីផ្សព្វផ្សាយច្បាប់បោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ និងច្បាប់ស្តីពីវិសោធនកម្មនៃច្បាប់នេះ នៅសាលារាជធានីភ្នំពេញដល់សាជិកក្រុមប្រឹក្សាខណ្ឌ និងក្រុមប្រឹក្សាសង្កាត់ នៅទូទាំងរាជធានីភ្នំពេញ។

ឯកឧត្តម អ៊ឹម សួស្តី បានមានប្រសាសន៍ថា ចាប់តាំងពីច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រត្រូវបានបង្កើតចុងឆ្នាំ១៩៩៧ រហូតមកដល់ពេលនេះ បានធ្វើវិសោធនកម្មចំនួន៧លើករួចមកហើយ ដែលលើកចុងក្រោយនេះត្រូវធ្វើវិសោធនកម្មចំនួន១៣មាត្រា ដោយផ្តោតលើចំណុចសំខាន់៣ **ទី១** បន្ថែមរយៈពេលនៃការពិនិត្យបញ្ជីឈ្មោះ និងចុះឈ្មោះបោះឆ្នោត ដែលពីមុនបន្ថែមតែ១៥ថ្ងៃនៅឆ្នាំដែលមានការបោះឆ្នោតសកល ប៉ុន្តែឥឡូវនេះបន្ថែមរហូតទៅដល់៣០ថ្ងៃ។ **ទី២** ការបិទផ្សាយបញ្ជីបោះឆ្នោតដំបូងនៅតាមសាលាឃុំ សង្កាត់ដើម្បីឱ្យប្រជាពលរដ្ឋមកមើល ពីមុនរយៈពេលប្តឹងតវ៉ា ឬជំទាស់មាន៥ថ្ងៃទេ ឥឡូវនេះ ច្បាប់វិសោធនកម្មថ្មីបន្ថែម៥ថ្ងៃទៀត។ ដូច្នេះរយៈពេលប្តឹងតវ៉ា ឬជំទាស់លើបញ្ជីបោះឆ្នោតដំបូងនេះមាន១០ថ្ងៃសម្រាប់ឆ្នាំដែលមានការបោះឆ្នោតសកល និង**ទី៣** ការងាររបស់គណៈកម្មការឃុំ សង្កាត់រៀបចំការបោះឆ្នោត គឺត្រូវឱ្យធ្វើការបូកសរុបលទ្ធផលបោះឆ្នោតនៅថ្នាក់ឃុំ សង្កាត់តែម្តង បន្ទាប់ពីបានទទួលរបាយការណ៍ពីគណៈកម្មការការិយាល័យបោះឆ្នោត ហើយបិទផ្សាយលទ្ធផលនេះនៅថ្នាក់ឃុំ សង្កាត់។ ចំណុចនេះកន្លងមក គ.ជ.ប បានធ្វើហើយ ប៉ុន្តែគ្រាន់តែពុំទាន់មានច្បាប់ចង្អុលឱ្យច្បាស់លាស់ ឥឡូវវិសោធនកម្មថ្មីបានដាក់បញ្ចូលរួចរាល់ហើយ។

ច្បាប់បោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ និងច្បាប់ស្តីពីវិសោធនកម្មនៃច្បាប់នេះ ត្រូវបានរដ្ឋសភាអនុម័តកាលពីថ្ងៃទី១១ ខែឧសភា ឆ្នាំ២០១១ នាសម័យប្រជុំរដ្ឋសភាលើកទី៦ នីតិកាលទី៤ និងព្រឹទ្ធសភាយល់ស្របតាមទម្រង់ និងគតិនៃច្បាប់នេះទាំងស្រុងកាលពីថ្ងៃទី៣១ ខែឧសភា ឆ្នាំ២០១១ នាសម័យប្រជុំពេញអង្គលើកទី៩ នីតិកាលទី២។ ហើយក្រុមប្រឹក្សាធម្មនុញ្ញបានពិនិត្យធម្មនុញ្ញភាព និងបានប្រកាសស្របនឹងរដ្ឋធម្មនុញ្ញតាមសេចក្តីសម្រេចលេខ១១៦/០០៤/២០១១ កបធ.ចចុះថ្ងៃទី១០ ខែមិថុនា ឆ្នាំ២០១១ និងត្រូវបានព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី ឡាយព្រះហស្តលេខាប្រកាសឱ្យប្រើប្រាស់ជាការប្រញាប់ កាលពីថ្ងៃទី០៤ ខែកក្កដា ឆ្នាំ២០១១៕



ឯកឧត្តម អ៊ឹម សូស្ដី ប្រធាន គ.ជ.ប ( រូបអាវខ្មៅ ) ចុះណែនាំការងារពិនិត្យបញ្ជីឈ្មោះ និងចុះឈ្មោះបោះឆ្នោត ដល់មន្ត្រីចុះឈ្មោះបោះឆ្នោត នៅសង្កាត់សំរោង





សកម្មភាពប្រជាពលរដ្ឋមកពិនិត្យបញ្ជីបោះឆ្នោតដំបូងនៅសាលាសង្កាត់បឹងទំពុន



សកម្មភាពប្រជាពលរដ្ឋមកសុំលិខិតបញ្ជាក់អត្តសញ្ញាណសម្រាប់បម្រើឱ្យការបោះឆ្នោតនៅសាលាសង្កាត់ស្ទឹងមានជ័យ កាលពីខែកញ្ញាកន្លងទៅ